**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ១៥៧០ [illegible]

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០១៦

# ជម្រាបមក

## ឯកឧត្តម អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត

**កម្មវត្ថុ** : ស្ដីពីការបង្កើត**ក្រុមការងារ**កែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់រដ្ឋបាលរាជធានីខេត្ត ដើម្បីជំរុញការអនុវត្ត ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០១៥-២០១៨។

**យោង** : លិខិតលេខ ១៨៤៦ មស.គករ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមជ្រាបថា ក្រសួងមុខងារសាធារណៈ បានស្នើសុំឲ្យរដ្ឋបាលរាជធានី ខេត្តនីមួយៗ បង្កើត**ក្រុមការងារ**កែទម្រង់រដ្ឋបាលសាធារណៈ ក្នុងគោលដៅសម្របសម្រួលការអនុវត្តកម្មវិធី យុទ្ធសាស្ត្រ និងសកម្មភាពកំណែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិ ឲ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។

ពាក់ព័ន្ធនឹងបញ្ហាខាងលើ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំអំពីដំណើរការរៀបចំបង្កើត**ក្រុមការងារ**កែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ដូចខាងក្រោម ៖

**១-សមាសភាព**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត រួមមាន៖

| | |
|---|---|
| -អភិបាល ឬអភិបាលរង នៃគណៈអភិបាលរាជធានីខេត្ត | ប្រធាន |
| -នាយករដ្ឋបាលសាលារាជធានី ខេត្ត | អនុប្រធាន |
| -ប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| -នាយកទីចាត់ការសាលារាជធានី ខេត្ត | សមាជិក |
| -តំណាងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត | សមាជិក |
| -តំណាងរតនាគាររាជធានី ខេត្ត | សមាជិក |
| -អភិបាល ឬអភិបាលរង នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ | សមាជិក |
| -តំណាងមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ចំនួន ០២រូប | ជាមន្ត្រីបង្គោល។ |

**២-តួនាទី ភារកិច្ច**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត រួមមាន៖

-ទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត ក្នុងការគ្រប់គ្រង និងដឹកនាំគ្រប់ការងារពាក់ព័ន្ធនឹងកម្មវិធី យុទ្ធសាស្ត្រ និងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈរបស់ថ្នាក់ក្រោមជាតិ។

-សម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ថ្នាក់ក្រោមជាតិ ជាមួយក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។

-សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពការងារ កែទម្រង់រដ្ឋបាលសាធារណៈ។

-រៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត។

-រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពឲ្យបានទៀងទាត់រៀងរាល់ត្រីមាសមកលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។

-រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈជូនក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈក្រសួងមហាផ្ទៃ ដើម្បីធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជ្រាប និងផ្តល់គោលការណ៍ណែនាំអនុវត្ត។

-ផ្តល់កិច្ចសហការ និងសម្របសម្រួលជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ តាមរយៈមន្ត្រីបង្គោល ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

-តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវរៀបចំ និងដាក់ចេញ**ដីកា** ស្តីពីការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរដ្ឋបាលរាជធានី ខេត្ត ឲ្យបានយ៉ាងយូរត្រឹមថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០១៦។ ដីកានេះត្រូវចុះហត្ថលេខាដោយអភិបាលរាជធានី ខេត្ត។

អាស្រ័យហេតុនេះ សូម**ឯកឧត្តម** ជ្រាប និងចាត់ចែងអនុវត្តឲ្យមានប្រសិទ្ធភាព។

សូម**ឯកឧត្តម** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>ចម្លងជូន</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- លេខាធិការដ្ឋាន គ.ជ.អ.ប

"ដើម្បីជូនជ្រាប"

- ឯកសារ-កាលប្បវត្តិ